# អំពី លទ្ធិស្ត្រីនិយម ក្នុងពេល ៥ នាទី!




# "Feminism"

## in five minutes!

ក្លាហាន
klahaan
brave

# សេចក្តីសង្ខេប

លទ្ធិស្រ្តីនិយមគឺជាទស្សនៈមនោគមន៍វិជ្ជានិងចលនាសង្គមដែលតស៊ូមតិឲ្យមានការផ្លាស់ប្តូរជាវិជ្ជមាននិងមានសមភាពផ្នែកសង្គមនយោបាយ បញ្ញានិងសេដ្ឋកិច្ចសម្រាប់បុគ្គលគ្រប់ភេទ។ អ្នកណាក៏អាចជាបុគ្គលស្រ្តីនិយមដែរហើយបុគ្គលគ្រប់រូបអាចចូលរួមជាមួយចលនានេះមិនថាគាត់មានភេទអ្វី ឬ អត្តសញ្ញាណយេនឌ័រមួយណាឡើយ។

ប៉ុន្តែរហូតមកទល់បច្ចុប្បន្ននេះនៅមានការជជែកដេញដោលនិងការភាន់ច្រលំជាច្រើនជុំវិញលទ្ធិស្រ្តីនិយមនេះ ដូច្នេះ អង្គការ ក្លាហាន បោះពុម្ពសៀវភៅនេះឡើងដើម្បីផ្តល់ការពន្យល់ដោយសង្ខេបមួយដែលប្រើប្រាស់ពេលវេលាត្រឹមតែប្រាំនាទីប៉ុណ្ណោះ មិត្តអ្នកអាននឹងយល់ច្បាស់និងអាចកំណត់បានដោយជាក់លាក់អំពីលទ្ធិស្រ្តីនិយម។

# Background to this booklet

Feminism is an ideology and social change movement which advocates for social, political, economic, and intellectual equality for all genders.

Everyone can be a feminist and anyone can join the movement regardless of sex or gender.

However, there's a lot of debate and confusion about the term 'feminism' – so in under five minutes, we would love to give you an introduction to what it really is (and isn't)!

# លទ្ធិស្ត្រីនិយម គឺ



ជាការធ្វើយ៉ាងណាដើម្បីធានាអោយស្ត្រី និង ក្មេងស្រីទទួលបានឱកាសស្មើរគ្នាទៅនិង បុរសព្រមទាំងអាចសម្រេចបាននូវក្តីសុបិន្ត របស់ពួកគេ។

*Feminism is:* *About making sure women and girls have equal opportunities in life, and can chase their dreams!*

# លទ្ធិស្ត្រីនិយម មិនមែន

ជាការដណ្តើម ឬដកយកសិទ្ធិពីបុរសនោះទេ។
ដូច្នេះ ទើបយើងជំរុញអោយបុរសក្លាយជា
បុគ្គលស្ត្រីនិយមផងដែរ។

Feminism is NOT: About taking rights away from men - That's why we encourage men to be feminists too!



# លទ្ធិស្ត្រីនិយម គឺ



ជាការបញ្ឈប់រាល់ការរើសអើងគ្រប់ទម្រង់រវាង បុរស និងស្ត្រីនៅកន្លែងការងារដើម្បីឲ្យបុគ្គលគ្រប់រូប អាចទទួលបានឱកាសស្មើរៗគ្នាក្នុងការចូលរួម និង ឬដឹកនាំស្ថាប័ន ឬសហគ្រាស ឬគណបក្សនយោបាយណាមួយជាដើម។

*Feminism is:* *About ending any discrimination between men and women in the workplace – so that everyone has the same opportunities to join and lead organisations, political parties or companies.*

# លទ្ធិស្ត្រីនិយម មិនមែន

ជាការធ្វើអោយស្ត្រីមានអំណាច លើសបុរសនោះទេ ដូច្នេះទើបយើងជំរុញអោយបុរសក្លាយជាបុគ្គលស្ត្រីនិយមផងដែរ។

*Feminism is NOT:* *About making women more powerful than men – that's why we encourage men to be feminists too!*



# លទ្ធិស្ត្រីនិយម គឺ



ជាការផ្លាស់ប្តូរទំនៀមទំលាប់ប្រពៃណីដែលទាក់ទងនិង
ការកំណត់តួនាទីយេនឌ័រ និងទស្សនៈសន្មត់ដែលមិនសមហេតុ
ផល ដែលបានបែងចែកតួនាទីរបស់បុរស និង ស្ត្រីកន្លងមក
ដើម្បីពួកគេអាចរួមចំណែកស្មើរៗគ្នាក្នុងតួនាទីមើលថែកូន
កិច្ចការផ្ទះ និងការរកចំណូល។

*Feminism is: About breaking down traditional gender roles and stereotypes so that men and women play a more equal role in raising kids, doing household chores and earning an income to support the family.*

# លទ្ធិស្ត្រីនិយម មិនមែន

ជាការដណ្តើមការងារគ្រប់យ៉ាងដែលបុរសធ្លាប់ធ្វើ ឬបង្ខំ អោយពួកគេនៅផ្ទះ និងចិញ្ចឹមកូននោះទេ។ វាជាការផ្តល់ឱកាសអោយបុគ្គលគ្រប់គ្នាមានជម្រើសស្មើរៗគ្នា។ ដូច្នេះទើបយើងជំរុញអោយបុរសក្លាយជាបុគ្គលស្ត្រីនិយមផងដែរ។

Feminism is NOT: About taking men's jobs, or forcing men to stay at home and raise kids. It's about everyone being able to make their own choices equally! That's why we encourage men to be feminists too!



# លទ្ធិស្ត្រីនិយម គឺ



ជាការបញ្ឈប់រាល់ទម្រង់នៃអំពើហិង្សាប្រឆាំងស្ត្រី កុមារ និងបុរស ដើម្បីបុគ្គលគ្រប់រូបអាចរស់នៅ ប្រកបដោយភាពថ្លៃថ្នូរ និងសុវត្ថិភាព។

**Feminism is:** About ending all forms of violence against women, children and men so that everyone can live their lives in dignity and safety.

# លទ្ធិស្ត្រីនិយម មិនមែន

ជាការស្វែងរកទម្រង់ណាមួយដើម្បីប្រព្រឹត្តអំពើ
ហិង្សាលើបុរសនោះទេ។ ដូច្នេះទើបយើងជំរុញ
អោយបុរសក្លាយជាបុគ្គលស្ត្រីនិយមផងដែរ។

Feminism is NOT: About making violence against men acceptable – That's why we encourage men to be feminists too!



# លទ្ធិស្ត្រីនិយម គឺ



ជាការលុបបំបាត់រាល់ទម្រង់នៃអំពើបៀតបៀនផ្លូវភេទ
នៅកន្លែងធ្វើការងារដើម្បីឲ្យបុគ្គលគ្រប់គ្នាអាចបំពេញ
ការងារដោយគ្មានភាពភ័យខ្លាច ឬរងអំពើហិង្សាផ្សេងៗ។

Feminism is: About ending sexual harassment at work so that everyone can do their job without fear of violence.

# លទ្ធិស្រ្តីនិយម មិនមែន

ជាការបញ្ឈប់បុរសមិនអោយមានការសន្ទនាជាមួយមិត្តស្រ្តីនៅកន្លែងការងារនោះទេ វាគ្រាន់តែធានាយ៉ាងណាឲ្យគ្រប់គ្នាមានអារម្មណ៍សុវត្ថិភាពនិងទទួលបានការគោរពគ្នាទៅវិញទៅមកនៅកន្លែងការងារ។

Feminism is NOT: About stopping men from talking to their women friends at work. It's about making sure everyone is comfortable and their boundaries are respected. That's why we encourage men to be feminists too!



សម្រាប់ព័ត៌មានបន្ថែម៖
For more information,
contact: info@klahaan.org

គាំទ្រដោយ៖
Proudly supported by:

rfsu

HEINRICH BÖLL STIFTUNG